# ឧបសម្ព័ន្ធទី ៤: ការខារចំការ*

## ១.ការធ្វើផែនការ

### ១.១ ករងារបច្ចេកទេស

មុនពេលចាប់ផ្ដើមកម្មវិធីដាំដើមឈើ ជាចាំបាច់ត្រូវធ្វើផែនការការងារឱ្យបានច្បាស់លាស់ ដែលយ៉ាងហោចណាស់ក្នុងផែនការនេះត្រូវដោះស្រាយនូវបញ្ហាមួយចំនួនដូចខាងក្រោម៖

- o តំបន់ដែលត្រូវដកចេញពីចំការឈើដាំ ដែលរួមមានទីជំរាលងាយរងការហូរច្រោះ តំបន់ទ្រនាប់នៅសងខាងផ្លូវទឹក តំបន់ការពារទេសភាពធម្មជាតិ និង តំបន់អភិរក្សធនធានសេនេទិកព្រៃឈើជាដើម ។
- o ការធ្វើផែនការធ្វើផ្លូវដឹកជញ្ជូន និង ផ្លូវភ្លើង ។
- o វិធីសាស្ត្រក្នុងការរៀបចំដីសំរាប់ដាំឈើ ការអនុវត្តការងាដាំដើមឈើ ការថែរក្សាចំការឈើ ការការពារការហូរច្រោះ និងប្រព្រិត្តកម្មរុក្ខវប្បកម្មនានា ។
- o វិធានការការការពារ និងគ្រប់គ្រងភ្លើងព្រៃ ។
- o វិធានការការពារទប់ទល់នឹងជំងឺ និងសត្វល្អិតបំផ្លាញ ។
- o ផែនការទីផ្សារ និងការប្រើប្រាស់ឈើ ។
- o ការកាន់កាប់ដីៈ ត្រូវកំណត់នូវភាពស្របច្បាប់នៃទីតាំងដែលត្រូវដាំឈើ ។ ត្រូវមើលផងដែរថាតើនៅមានជំលោះអំពីការកាន់កាប់ដីដែលមិនទាន់បានដោះស្រាយដែរឬទេ មុននឹងចាប់ផ្ដើមដាំឈើ? ត្រូវរៀបចំកិច្ចសន្យា ដើម្បីធានាការប្រើប្រាស់ដី និង ធនធានទឹក ។
- o ទំហំចំការឈើៈ មិនមានគោលការណ៍កំណត់ច្បាស់លាស់អំពីទំហំចំការដាំឈើទេ ។ ជាទូទៅកាលណាចំការឈើកាន់តែធំនោះការចំណាយក្នុងមួយឯកត្តាដីមានទំហំតូចជាង ។ ការផ្លាស់ប្ដូរដីឬក៏ការចូលហ៊ុនគ្នាក្នុងការធ្វើវិនិយោគអាចចាត់ទុកថាធ្វើឱ្យការចំណាយក្នុងការបង្កើតចំការឈើដាំមានកំរិតទាប ។
- o កំលាំងពលកម្មៈការងារដាំឈើ ភាគច្រើនត្រូវអនុវត្តដោយកសិករនៅក្នុងកំឡុងពេលក្រៅពីរដូវដាំដុះ ។ ប្រសិនបើចំការឈើមានទំហំធំពេកដែលពិបាកគ្រប់គ្រងនោះគេត្រូវជួលកម្មករបន្ថែមពីក្រៅ ។ បញ្ហានេះគេច្រើនជួបប្រទះនៅពេលរៀបចំចំការនិងពេលដាំដុះ ។ ការជួលកំលាំងពលកម្មពីក្រៅត្រូវផ្ដល់ទីកន្លែងសំរាប់ស្នាក់នៅផងដែរ ។
- o ត្រូវធ្វើកាលវិភាគក្នុងការបង្កើតចំការឈើដាំ ដែលរួមបញ្ចូលដោយៈ
    - កាលបរិច្ឆេទសមស្រប សំរាប់ការកាប់សំអាតចំការ

---

*(*): ចំណុចខ្លះនៅក្នុងផ្នែកនេះត្រូវបានដកស្រង់ និង សំរួលពីForestry / Fuelwood Research and Development Project.1994.*

- កាលបរិច្ឆេទសមស្រប សំរាប់ការរៀបចំចំការ
- កាលបរិច្ឆេទសមស្រប សំរាប់ការបេះប្រមូលគ្រាប់ពូជ និងការសាបគ្រាប់ពូជ
- កាលបរិច្ឆេទសមស្រប សំរាប់ការដាំឈើនៅក្នុងចំការ
- កាលបរិច្ឆេទសមស្រប សំរាប់ការដាក់ជី និងការដាំជួស ។

o ត្រូវគិតគូរអំពីការចូលរួមរបស់សហគមន៍មូលដ្ឋាន ទាំងនៅក្នុងដំនាក់កាលធ្វើផែនការ និងការអនុវត្ត ជាក់ស្តែងដើម្បីលើកទឹកចិត្តពួកគេឱ្យចូលរួមសហការ និង បង្កើនប្រាក់ចំណូលផងដែរ ។ ត្រូវគិតគូរអំពី ការទទួលស្គាល់នូវសិទ្ធប្រើប្រាស់ផល និង អនុផលព្រៃឈើជាប្រពៃណីរបស់សហគមន៍មូលដ្ឋាន ។

### ១.២ ចំណាយ

o ការបង្កើតចំការឈើដាំទោះបីជាតូចក្តីត្រូវចំណាយខ្ពស់ណាស់ ។ ការចំណាយខ្លះដូចជាទិញដីជាដើមមិន ចាំបាច់ទេសំរាប់កសិករដែលមានសិទ្ធិនៅលើដីដែលបំរុងនឹងដាំឈើ ។ ការចំណាយផ្សេងៗទៀត ពិបាកនឹង ចៀសវាងណាស់ដូចជាការទិញឧបករណ៍សំភារៈសំរាប់ដាំឈើ ការជួលដី ជួលកម្មករ ការកសាងផ្លូវ ការធ្វើរបង ការថែរក្សាការពារ និងការដឹកជញ្ជូន ។

o ប្រសិនបើបានធ្វើផែនការច្បាស់លាស់នោះសោហ៊ុយចំណាយនឹងត្រូវកាត់បន្ថយ ។ ក្នុងន័យនេះត្រូវសួរខ្លួនឯងថា:
- តើការរៀបចំដីធ្វើឡើងដោយកម្មករឬដោយត្រាក់ទ័រ?
- តើត្រូវការរបងប៉ុន្មាន? តើប្រើសំភារៈសំណង់អ្វី ហើយថ្លៃប៉ុន្មាន? ។ល ។

## ២. ការជ្រើសរើសទីតាំងសំរាប់ដាំឈើ

### ២.១ ភាពដែលអាចចូលដល់

ដើម្បីកាត់បន្ថយសោហ៊ុយចំណាយលើការសាងសង់ផ្លូវ គេត្រូវរើសទីតាំងណាដែលទាមទារការកសាងផ្លូវ តិចបំផុត ។ ការដឹកជញ្ជូនក៏មានតំលៃថ្លៃផងដែរ ដូច្នេះចំការដាំឈើគួរតែ:

o ឋិតនៅជិតផ្លូវមេ និងផ្លូវបន្ទាប់

o នៅជិតប្រភពផ្គត់ផ្គង់និងតំរូវការ

o នៅជិតភូមិ

o នៅជិតទីផ្សារលក់ផលិតផលឈើ

### ២.២ សណ្ឋានដី

សណ្ឋានដីសំដៅទៅលើ ជំរាលនៃទីតាំង ភាពមានដុំថ្មឬផ្ទាំងថ្ម រយៈកំពស់ និងការប្រឈមទៅនឹងពន្លឺព្រះ អាទិត្យ ។ ជំរាលគឺជាធាតុសំខាន់មួយដែលត្រូវពិចារណា ។ ទីតាំងដែលមានជំរាលខ្លាំងតែងតែមានដីស្រទាប់លើរាក់ ហើយងាយរងការហូរច្រោះ ។ នៅក្នុងទីតាំងទាំងឡាយណាដែលមានកំពស់ទឹកភ្លៀងប្រចាំឆ្នាំច្រើន ជាង ២ 000 មម

ហើយមានជំរាលខ្លាំង ទាមទារឱ្យមានការរៀបចំដីជាថ្នាក់ៗឬក៏ ប្រើវិធានការណ៍ផ្សេងៗទៀត។ ការងារនេះអាស្រ័យទៅលើតំរូវការនៃការគ្រប់គ្រង តំលៃនៃប្រភេទឈើដាំ និងចំណាយសំរាប់ពលកម្មក្នុងការដាំឈើ។

## ២.៣ ដី

### ២.៣.១ ប្រភេទដី

នេះជាលក្ខណៈសម្បត្តិមួយសំខាន់។ ដីមមោក និង ដីល្បាប់ជ្រៅជាប្រភេទដីល្អបំផុតសំរាប់ដាំឈើ។ ដីមមោកជារឿយៗច្រើនជួបប្រទះនៅផ្នែកខាងក្រោមនៃជំរាលដែលកើតឡើងពីការប្រមូលផ្តុំនៃដីនិងកំទេចកំទីរុក្ខជាតិ។ ដីល្បប់កើតឡើងពីកំទេចកំណដែលរងធ្លាក់នៅស្រទាប់ក្រោមនៃផ្ទៃទឹក ដែលជាទូទៅរួមផ្សំដោយភក់និងដីឥដ្ឋ។ ដីដែលនៅពាក់កណ្តាលជំរាលក៏សមស្របសំរាប់ដាំ ឈើផងដែរ។ នៅក្នុងតំបន់ដែលមាន ស្រទាប់ថ្មបាយក្រៀមនៅក្បែរផ្ទៃដីបង្កការលំបាកដល់ការចាក់ឬសចុះទៅក្រោម ហើយដីប្រភេទនេះមិនសមស្របចំពោះការដាំឈើជាលក្ខណៈពាណិជ្ជកម្មទេ។ ក៏ប៉ុន្តែ សំរាប់គោលបំណងការពារការហូរច្រោះដី គេគួរជ្រើសរើសប្រភេទស្មៅនិងគុម្ពព្រឹក្សមកដាំនៅតំបន់នោះ។

### ២.៣.២ រចនាសំព័ន្ធដី

ដីដែលសមស្របបំផុតសំរាប់ការងារដាំឈើគឺជាប្រភេទដីល្បប់ដែលមានវាយនភាពមធ្យម។ ដីខ្សាច់ ដីឥដ្ឋនិងដីហាប់ មិនសមស្របសំរាប់ការងារដាំឈើទេ។ ដីដែលមានរចនាសំព័ន្ធដីអន់ ឬដីជាំទឹក អាចកែលំអបានដោយការជីកប្រឡាយបង្ហូរទឹកដើម្បីបន្ថយកំពស់ទឹកក្រោមដី។

### ២.៣.៣ ជីជាតិដី

ដីល្បប់មិនមែនជានិច្ចកាលសុទ្ធតែមានជីជាតិទេ។ការដាក់ជីគឺជាការចាំបាច់។ នៅក្នុងតំបន់ដែលមានកំទេចកំណច្រើនពេកអាចមានកង្វះសារធាតុចិញ្ចឹមក្នុងរយៈពេលបណ្តោះអាសន្នមួយ។ នៅក្នុងតំបន់ដែលមានបរិមាណទឹកភ្លៀងខ្ពស់ក៏អាចមានកង្វះសារធាតុចិញ្ចឹមជាពិសេសចំពោះប្រភេទដីខ្សាច់។ សំរាប់ប្រភេទដីខ្សាច់គេត្រូវដាក់ជីសរីរាង្គដើម្បីបង្កើនជីជាតិដី និង រចនាសម្ព័ន្ធដី។

### ២.៣.៤អាស៊ីត

ដីដែលមិនមានកំរិតអាស៊ីតខ្លាំងពេកឬបាសខ្លាំងពេក (ណើត) សមស្របបំផុតសំរាប់ការងារ ដាំឈើ។ ដីដែលមានអាស៊ីតតិចតួចឬអាល់កាឡាំងតិចតួចក៏សមស្របសំរាប់ការងារដាំឈើផងដែរប្រសិនបើគេជ្រើសរើសប្រភេទឈើឱ្យបានសមស្របសំរាប់លក្ខខណ្ឌនេះ។

## ៣. ធាតុអាកាស

- ទិដ្ឋភាពពីរដែលគួរពិចារណាក្នុងការជ្រើសរើសទីតាំងដាំឈើគឺៈ បរិមាណនិងរបាយទឹកភ្លៀង និង កំរិតសីតុណ្ហភាពអតិបរមានិងអប្បបរមា។ កត្តាទាំងពីរនេះកំណត់នូវភាពសមស្របសំរាប់ប្រភេទឈើ។

o ពត៌មានលំអិតអំពីបរិមាណនិងរបាយទឹកភ្លៀងនិងកំរិតសីតុណ្ហភាពអាចស្វែងរកបានតាមរយៈនាយកដ្ឋានឧត្តុនិយម ឬពីស្ថានីយ៍ឧត្តុនិយមប្រចាំតំបន់និមួយៗ ។

## ៤. ការរៀបចំដីសំរាប់ដាំឈើ

កម្មវត្ថុនៃការរៀបចំដីគឺៈ (១)ៈកាប់សំអាតរុក្ខជាតិចេញពីទីតាំងដែលត្រូវដាំឈើ (២)ៈបង្កភាពងាយស្រួលដល់ការងារដាំឈើ (៣)ៈ កាត់បន្ថយការដុះលូតលាស់នៃស្មៅ (៤)ៈ កាត់បន្ថយការហូរច្រោះដីដោយការបង្កើតរបាំងទប់នៅតំបន់ដែលមានការហូរច្រោះ (៥)ៈ ដើម្បីការពារសំណើមដីឱ្យបានជាអតិបរមានៅតំបន់ស្ងួត (៦)ដើម្បីសំរួលការចាក់ឫសនៃរុក្ខជាតិ (៧)ៈ ដើម្បីសំរួលដល់ការដុះលូតលាស់នៃកូនឈើ (៨)ៈ ដើម្បីដកយកចេញនូវឧបសគ្គនានាពីផ្ទៃដី (៩)ៈដើម្បី បង្កើនភាពស្រស់ទឹកនៅក្នុងតំបន់ដាំទឹក ។

កំរិតនៃការរៀបចំដីប្រែប្រួលអាស្រ័យទៅលើ (១)ៈប្រភេទឈើដែលត្រូវដាំ (២)ៈរុក្ខជាតិដែលមាននៅលើផ្ទៃដី (៣)ៈលក្ខខណ្ឌនៃទីកន្លែង (៤) ការចំណាយ និងកត្តាផ្សេងៗទៀត ។ នៅក្នុងតំបន់ជំរាលដែលមានការហូរច្រោះដី ការរៀបចំដីត្រូវប្រុងប្រយ័ត្នជាទីបំផុត ។ ជាទូទៅការរៀបចំដី មានដំណើរការជាជំហានៗ ដូចខាងក្រោមៈ

### ៤.១ ការកាប់សំអាតដើមឈើ

ជានិច្ចកាលគេចាំបាច់ត្រូវកាប់សំអាតរុក្ខជាតិចេញពីទីតាំងដែលត្រូវដាំឈើ ។ ប្រភេទឈើមួយចំនួនទាមទារឱ្យមានកំរិតម្លប់ពីខាងលើនិងពន្លឺថ្ងៃខ្លះពីចំហៀង ។ ការកាប់សំអាតផ្ទៃដីទាំងស្រុងអាចអនុវត្តសំរាប់ការដាំ ឈើ ដែលទាមទារពន្លឺថ្ងៃ ។ ប្រសិនបើមិនចាំបាច់ ឬការចំណាយមានទំហំធំពេក គេអាចកាប់សំអាតចំការ ដោយបើកប្រលោះព្រៃជាខ្សែបន្ទាត់ឆ្លាស់ៗគ្នាដែលខ្សែនិមួយៗមានទទឹង ១.៥ ម ។ ប្រសិនបើមានដើមឈើ នៅមានដុះរាយប៉ាយមួយៗ ហើយ ពពួកគុម្ពព្រឹក្សមិនសូវក្រាស់ ការកាប់សំអាតប្រហែលជាមិនចាំបាច់ទេ ។

<u>ការកាប់សំអាតចំការដោយបើកប្រលោះព្រៃជាខ្សែបន្ទាត់ (strips)</u>ៈនៅក្នុងតំបន់វាលស្មៅប្រហែលជាមិនចាំបាច់កាប់សំអាតរុក្ខជាតិចោលទេលើកលែងតែទីតាំងនោះគ្របដណ្តប់ដោយស្បូវ ។ នៅក្នុងតំបន់ដែលមានការហូរច្រោះ ការកាប់សំអាតស្មៅចេញទាំងអស់មិនចាំបាច់ទេ ។ នៅក្នុងតំបន់វាលស្មៅដែលរុក្ខជាតិមានកំពស់លើសពីមួយម៉ែត្រ គេអាចកាប់សំអាតដោយការបើកប្រលោះព្រៃខ្សែជាបន្ទាត់ ។ ស្មៅកាន់តែខ្ពស់ នោះទទឹងប្រលោះព្រៃដែលត្រូវបើកក៏កាន់តែធំ ។ ការធ្វើរបៀបនេះមានសារសំខាន់ណាស់ នៅតំបន់ដែលពុំមានការដុះលូតលាស់ដោយធម្មជាតិ ។

<u>ការកាប់សំអាតចំការដោយបើកជាខ្សែប្រលោះព្រៃធំៗ (patches)</u>: វិធីសាស្ត្រនេះអាចអនុវត្តទាំងនៅក្នុងតំបន់វាលស្មៅនិងទាំងនៅតំបន់ព្រៃរេចរិល ។ គេអាចដុតសំអាតនៅតាមប្រលោះព្រៃនិមួយៗនោះ ដែលត្រូវដាំឈើ ។

### ៤.២ ការគាស់គល់ឈើ

ការគាស់គល់ឈើចេញគឺជាការចាំបាច់នៅពេលដែលមានការរៀបចំដីដោយគ្រឿងចក្រ ឬក៏មានការចំលងជំងឺ

ពុកឬស ឬពុកដើមទៅដល់ដំណុះឈើស្រករក្រោយ។ ការគាស់គល់ឈើចេញ រួមមានការជីកឬស និងដកយកគល់ចេញ។ ការដកយកគល់ចេញត្រូវចំណាយខ្ពស់ណាស់ ដូច្នេះគេមិនអនុវត្តជាទូទៅទេ ប៉ុន្តែប្រសិនបើគល់ចាស់នោះមានជំងឺ ចាំបាច់ត្រូវដកចេញដើម្បីចៀសសវាងការចំលងរោគ។ ការរៀបចំដីដោយគ្រឿងចក្រត្រូវចំណាយសោហ៊ុយខ្ពស់ជាងការរៀបចំដីដោយដៃ ហើយមិនសមស្របចំពោះចំការឈើតូចៗទេ។

### ៤.៣ ការគរកាកសំណល់

កាកសំណល់ដែលបានមកពីការកាប់សំអាតចំការ ត្រូវគរទុកឱ្យបានសមស្រប។ ប្រជាជនមូលដ្ឋានគួរអនុញ្ញាតឱ្យប្រមូលកាកសំណល់នេះយកទៅប្រើប្រាស់ដោយឥតគិតថ្លៃ ហើយប្រសិនបើនៅមានសលល់កាកសំណល់ ទៀតគេគួរគរដុតដោយសារវារំខានការងាររៀបចំដី និងមានផលអាក្រក់ដល់កូនឈើដាំ និងកូនឈើដេលដុះ ដោយធម្មជាតិដោយបាំងម្លប់កូនឈើ ជាឧបសគ្គដល់ការប្រើគ្រឿងចក្រ និងអាចជាប្រភពជំងឺរលួយឬស និងរលួយដើម។

## ៥. របៀបដាំឈើ

### ៥.១ ការបោះបង្គោល

ទីតាំងរណ្តៅដែលត្រូវដាំឈើត្រូវដាក់សញ្ញាសំគាល់ដោយដោតកំណាត់បង្គោលឫស្សីឬបង្គោលឈើដែលអាចរកបាននៅនឹងកន្លែង។ ប្រសិនបើការកំណត់រណ្តៅធ្វើឡើងដោយប្រើខ្សែពួរ នោះការប្រើបង្គោលឫស្សីមិន ចាំបាច់ទេ។

### ៥.២ ការជីករណ្តៅ

គួរជីករណ្តៅយ៉ាងហោចណាស់មួយសប្តាហ៍មុននឹងដាំឈើ ដើម្បីឱ្យកំដៅថ្ងៃបំបែកសារធាតុសរីរាង្គនៅក្នុងរណ្តៅហើយសំលាប់វីរុសនិងជំងឺផ្សេងៗទៀត។ ជាការល្អរណ្តៅត្រូវជីកឱ្យធំដើម្បីឱ្យកូនឈើចាក់ឬសបានជ្រៅ និងស្រូបជីជាតិបានច្រើន។ រណ្តៅត្រូវមានរាងជាការេទំហំ ៣០ x ៣០ សម និងមានជំរៅ ៣០ សម ។ កាយអាចម៍ដីស្រទាប់លើដាក់ដោយឡែក និងដីស្រទាប់ក្រោមដាក់ដោយឡែក រួចកាយសសុសដីបាតរណ្តៅឱ្យល្អ។ នៅពេលដាំ ត្រូវកាយដីស្រទាប់លើលុបរណ្តៅមុន។

### ៥.៣ ការដាំកូនឈើ

- ត្រូវហែកថង់ប្លាស្ទិកចេញពីកូនឈើដោយថ្នមៗដោយកាត់(ឆូត) ថង់នឹងឡាមដែលមុតល្អ។ជៀសវាងការខូចខាតឫសកូនឈើដោយព្យាយាមថែរក្សាដីដែលស្រោបឫសកូនឈើកុំឱ្យបែក។
- ដាក់កូនឈើទៅក្នុងរណ្តៅ ហើយលប់ដីត្រឹមកគល់កូនឈើ។ នៅតំបន់ក្តៅហើយស្ងួតត្រូវកប់ដាំកូនឈើឱ្យជ្រៅតាមដែលអាចធ្វើបាន ដោយទុកតែផ្នែកដើមបន្តិចលេចផុតពីដី ធ្វើដូច្នេះអាចធានាបានថាឫសកូនឈើចាក់ជ្រៅទៅក្នុងដី ហើយកាត់បន្ថយការភាយហួតចំហាយទឹក។
- ត្រូវប្រុងប្រយ័ត្នកុំឱ្យបែកដី បាក់ដើម និងខូចឫស

o បង្ហាប់ដីនៅជុំវិញកូនឈើ

o នៅតំបន់ក្តៅហើយស្ងួតត្រូវធ្វើរណ្តៅនៅជុំវិញកូនឈើដើម្បីធានាការរក្សាសំណើមជាអតិបរមា។

## ៥.៤ គំរូនៃការដាំកូនឈើ

ជនិច្ចកាលត្រូវដាំឈើជាជួរដើម្បីសំរួលដល់ការថែរក្សាការពារ។ នៅតំបន់ភ្នំ ត្រូវដាំឈើជាជួរកែងនឹងជំរាលភ្នំដើម្បីការពារកាហូរច្រោះ។ ត្រូវធានាកូនឈើរត់ត្រង់ជួរ និងរក្សាគំលាតស្មើៗគ្នា។

គំរូនៃការដាំឈើសំខាន់ៗចំនួនបីគឺៈ

o ដាំជារាងការេៈ គំលាតរវាងជួរកូនឈើ និងគំលាតរវាងដើមឈើនៅក្នុងជួរស្មើគ្នា

o ដាំជារាងចតុកោណកែងៈ និយមប្រើនៅតំបន់ណាដែលមានបន្សល់ទុកគំរបរុក្ខជាតិខ្លះសំរាប់ការពារការហូរច្រោះ។

o ការដាំជាជួរនៅតាមខ្សែរយៈកំពស់ៈជារបៀបដែលកែសំរួលពីការដាំជារាងចតុកោណកែង ដើម្បីឱ្យត្រូវនឹងខ្សែរយៈកំពស់។

## ៥.៥ គំលាត

ការកំណត់គំលាតកូនឈើផ្អែកទាំងស្រុងលើកត្តាសេដ្ឋកិច្ចនិងទីផ្សារ ។ការដាំញឹកពេកនឹងត្រូវចំណាយខ្ពស់ពីព្រោះត្រូវចំណាយកូនឈើច្រើន ដោយឡែកការដាំឈើរង្វើលពេកជាការប្រើប្រាស់ដីមិនអស់លទ្ធភាព។

គំលាតកូនឈើអាស្រ័យលើប្រភេទឈើ និងផលិតផលដែលគេចង់បាន។ ឧទាហរណ៍ៈ

o អុសៈ១-២ម។ គោលបំណងនៅទីនេះគឺបង្កើនទិន្នផលជាអតិបរមានៅក្នុងរយៈពេលខ្លី។ គំលាតនេះសមស្របចំពោះប្រភេទឈើតូចៗ និងមធ្យម។

o ម្សៅក្រដាសៈ ២-៣ម។ គោលបំណងនៅទីនេះគឺបង្កើនទិន្នផលជាអតិបរមានៅក្នុងរយៈពេលពី ៥-១៥ ឆ្នាំនៃវដ្តអាជីវកម្ម។ គំលាតប៉ុននេះអនុញ្ញាតឱ្យមានការក្រើមែកដែលមានទំហំ ១-៤ សម សំរាប ធ្វើអុសដុត។

o ឈើអារ ឬក្តារបន្ទះៈ ២.៥-៥ ម។ គោលបំណងនៅទីនេះគឺបង្កើនទិន្នផលឈើមូលដែលយ៉ាងហោចណាស់មានទំហំអង្កត់ផ្ចិត ៣០ សម។

កត្តាជីវសាស្ត្រនៃប្រភេទឈើនិមួយៗកំណត់គំលាតដែលត្រូវដាំៈ

o ល្បឿនលូតលាស់ៈប្រភេទដែលដុះលូតលាស់លឿន ការប្រកួតប្រជែងចាប់ផ្តើមឆាប់ ដូច្នេះទាមទារឱ្យមានគំលាតធំ។

o របៀបបែកមែកៈ ប្រភេទដែលបែកមែកកែងនឹងដើមឈើទាមទារឱ្យមានគំលាតធំជាងប្រភេទធម្មតា

- តំរូវការឱ្យមានគំរបព្រៃឆាប់ដើម្បីសំលាប់រុក្ខជាតិឥតប្រយោជន៍៖ នៅក្នុងតំបន់មានភ្លៀងច្រើន ដែលស្មៅដុះលូតលាស់ឆាប់រហ័ស គេត្រូវដាំឈើក្នុងគំលាតមួយញឹកជាងតំបន់ដែលស្មៅ ដុះយឺត ។
- ឥទ្ធិពលនៃការបញ្ចេញទឹក៖នៅក្នុងតំបន់ដីជាំទឹក( ដែលរំខានដល់ការដុះលូតលាស់នៃកូនឈើ) គេត្រូវដាំឈើក្នុងគំលាតមួយញឹកបំផុត ។

## ៥.៦ ពេលវេលានៃការដាំឈើ

- ពេលវេលាប្រសើរបំផុតសំរាប់ដាំឈើគឺ នៅដើមរដូវភ្លៀង ដែលប្រែប្រួលខុសគ្នាបន្តិចបន្តួចរវាងតំបន់អេកូឡូស៊ីនិមួយៗ ( ដើមខែឧសភា-ដើមខែមិថុនា) ។
- ដាំឈើនៅថ្ងៃដែលមេឃស្រទុំជាជាងដាំនៅពេលដែលមេឃក្ដៅហែងឬមានខ្យល់-ព្យុះ ។

## ៥.៧ ការដាំជួសកូនឈើ

- ត្រូវត្រៀមបំរុងកូនឈើ ដែលមានសុខភាពល្អប្រមាណ ២០% សំរាប់ដាំជួស ។
  ចំនួនកូនឈើដែលត្រូវដាំជួស = ចំនួនកូនឈើងាប់គិតជាភាគរយ x ចំនួនកូនឈើដែលដាំសរុប ។
- ការដាំជួសកូនឈើអាចធ្វើឡើងចំនួនពីរដងគឺ លើកទីមួយបន្ទាប់ពីដាំរយៈពេលមួយខែ និងលើកទីពីរនៅរដូវដាំឈើឆ្នាំបន្ទាប់ ។
- ជាទូទៅ សំរាប់ការដាំឈើជាទ្រង់ទ្រាយធំ គេដាំជួសកូនឈើនៅពេលដែលអត្រារស់ទាបជាង ៧០% ។

## ៥.៨ ការដាំឈើដោយគ្រាប់ផ្ទាល់

ការដាំឈើដោយគ្រាប់ផ្ទាល់ ត្រូវចំណាយសោហ៊ុយតិចជាងការដាំដោយកូនឈើ ។ គេត្រូវពិចារណាលើការដាំឈើដោយគ្រាប់ផ្ទាល់នៅពេលដែលប្រភេទដែលត្រូវដាំមានអត្រាដំណុះខ្ពស់ កូនឈើដុះលូតលាស់លឿន អាចជៀសផុតពីការប្រណាំងប្រជែងពីរុក្ខជាតិឯទៀត ហើយគ្រាប់ពូជសំបូរនិងមានតំលៃថោក ។ ការដាំឈើដោយគ្រាប់ផ្ទាល់អាចអនុវត្តបានចំពោះប្រភេទអង្កាញ់ នាងនួន ក្រញូង ប្រភេទសិម្ពិកូលខ្លះដូចជាកន្ទុំថេត និង ភាគច្រើននៃប្រភេទអាកាស្យា ។ បច្ចេកទេសនៃការដាំឈើដោយគ្រាប់ផ្ទាល់មានដូចខាងក្រោម៖

- ការសាបគ្រាប់ជាជួរ៖ វិធីសាស្ត្រនេះងាយស្រួលចំពោះដីវាលដែលបានភ្ជួររាស់ ឬតំបន់ដែលបានភ្ជួររាស់ជាជួរ ។ គ្រាប់ពូជអាចសាបព្រោះដោយដៃ ឬដោយប្រើដំបងឈើដើម្បីជីករណ្ដៅដែលមានជំរៅ ២-៥ សម ហើយក្នុងរណ្ដៅនិមួយៗគេដាក់គ្រាប់ពី ២-៣គ្រាប់អាស្រ័យទៅតាមប្រភេទឈើ ។ គំលាតរវាងជួរកូនឈើ និងគំលាតរវាងកូនឈើដាំ អាស្រ័យទៅតាមប្រភេទឈើ ល្បឿនលូតលាស់ និងវិធីសាស្ត្រ ថែរក្សា ។
- ការសាបគ្រាប់ពូជជាជ្រុំ៖ វិធីនេះគ្រាប់ពូជត្រូវបានសាបនៅលើផ្ទៃដីចន្លោះព្រៃតូចៗដែលបានភ្ជួររាស់ និងក្នុងគំលាតមួយច្បាស់លាស់តាមការចង់បាន ហើយក្នុងរណ្ដៅនិមួយៗគេដាក់គ្រាប់ពី ២-៣គ្រាប់ ។

- o ការសាបគ្រាប់នៅលើពំនូកដីៈ វិធីសាស្ត្រនេះអនុវត្តចំពោះតំបន់ដីជាំទឹក។ ក្នុងករណីនេះត្រូវជីកប្រឡាយបង្ហូរទឹកចេញដោយគរអាចម៍ដីនៅសងខាងប្រលាយ រួចពង្រាបដីឱ្យស្មើ បន្ទាប់មកសាបគ្រាប់ពូជនៅលើខ្នងប្រលាយ។

## ៥.៩ ការដាំឈើនៅលើទីតាំងដែលមានឧបសគ្គ

ទីតាំងខ្លះមានវត្តមាននូវឧបសគ្គនានាដូចជាៈមានបរិមាណទឹកភ្លៀងតិចតួច ប្រឈមមុខនឹងខ្យល់បក់ខ្លាំង ទីតាំងដែលរងសំណឹកអស់ស្រទាប់ដីខាងលើ ទីតាំងដែលរងការបំផ្លាញហួសហេតុដោយហ្វូងគោក្របី ឬត្រូវភ្លើងឆេះជារៀងរាល់ឆ្នាំ។

មានមធ្យោបាយសំខាន់ៗបីដើម្បីដោះស្រាយ និងជំនះឧបសគ្គនានានៅក្នុងទីតាំងលំបាកៗ ដូចជាៈ

- o ដោយប្រើប្រាស់ប្រភេទឈើ និងប្រភពកំណើតដែលមាននៅក្នុងទីតាំងនោះ។ ការជ្រើសរើសប្រភេទឈើឱ្យបានសមស្រប គឺជាការងារសំខាន់បំផុត។
- o កែលំអទីតាំងនោះដោយកែលំអផ្ទៃដីខាងលើ បង្កើនសំណើមដី បង្កើនសារធាតុចិញ្ចឹម ។ល។
- o ធ្វើរបងឬប្រើមធ្យោបាយផ្សេងទៀតដើម្បីការពារការចូលរុករានទន្ទ្រានពីសត្វពាហនៈ។